Khmer Story Lovers

ប្រលោមលោកប្រឌិតតាមសម័យបុរាណ ចិន Vann[illegible]

## ប្រលោមលោកចេញផ្សាយរៀងរាល់ថ្ងៃ



ប្រែសម្រួល: អ.គីមសាន

តម្លៃ ៣៛០០

បោះពុម្ពផ្សាយចេញពីក្រុមអ្នកនិពន្ធ «មាតុភូមិ» ភ្នំពេញ

លេខ ១៧

ស៊ីផានដើរទៅអង្គុយលើកន្សែងទូកស្រមៃទៅឆ្ងាយ.. ដល់ពាក់កណ្ដាលអធ្រាត្រ នាយព្រានទីនគុនស្រែកពីក្នុងទូកមកថា :

-លោកតា, លោកតា ! សូមមេត្តាលើកលែងទោសឲ្យបងផានផងណា ! សុំលោកតាកុំសម្លាប់គាត់ ។

ស៊ីផានស្ទុះក្រោករត់ទៅក្នុងទូក ឃើញទីនគុនចាប់ចុងទីនមិនហួសបី ។ នាយឃើញស្អិតៗ ហើយនាងស្រែកដដែលៗថា លោកតាកុំសម្លាប់បងផានៗ...

ស៊ីផានប្រុងលូកដៃទៅចាប់ខ្នាំមីតាចរលោកតាតាមទីនគុនប្រាប់ តែពេលនោះ នាយនឹកឃើញ មិនវាន់ហូ ដែលរមួលខ្លួនកំរើកមិនរួច ក៏ភ័យភ្ញាក់ផ្អើលនឹកថា :

-បើចាប់ខ្នាំគាត់តាមទីនគុន លោកតាកាចក្លាយជាជនពិការ ហើយជាប់ចិត្តដែរ ? ទេកុំធ្វើបាបគាត់ ។

មាណពគិតឃើញដូច្នេះ ទើបរត់ចេញមកវិញដាក់គួចប៉ុក ទបក្បាលទាំងភ័យស្លុត ។ ទីនគុនឃើញស៊ីផានចូលមកដូចសត្វនាងត្រេកអរណាស់, ស្រាប់តែឃើញមាណពរញ្ជួក ហើយចេញទៅវិញបាត់, នាងភ័យអន្ទះអន្ទែងដោយគោលបំណងមិនបានសម្រេច ។

ស៊ីផានកំពុងភ័យក្ដុកក្ដាក់ ស្រាប់តែព្រានទីនគុនស្រែកថ្ងូរ :

–អូយលោកតាអើយ! ម៉េចខ្ញុំមកជួបលោកតាស្អិតអ៊ីចឹង?    ធ! អម្បាញ់មិញខ្ញុំយល់សប្តិអាក្រ
ណាស់,    ឃើញលោកតាទះបង្កានមួយដៃយ៉ាងខ្លាំង,    ខ្ញុំអង្វរយ៉ាងណាក៏លោកតាមិនព្រម .
ម៉ឺ!  សាធុទៅលោកអើយ! គ្រាន់តែយល់សប្តិសោះខ្ញុំភ័យ ។

ស៊ីផាននួរត្រូវខ្យាកអឹកសរសើរទីនគុនថាប្រសប់និយាយ,  បេះកុហកមែន! ទោះមិនជួយនា
ក៏នាងចេះកែពាក្យសំដីពីរោះគោរពលុបបំបាត់កំហុសដែរ ។   ទីនមិនហួសបីឆ្លើយ:

– ទៅឯងយល់សប្តិក៏ដោយមិនយល់សប្តិក៏ដោយ,    ស្អែកនេះដល់ថ្ងៃសន្យាហើយ
ចាំមើលអាប្រមាត់កែប៉ាយរាន់បានឃើញឬទេ ?

ទីនគុនដកដង្ហើមធំ :

– ខ្ញុំដឹងច្បាស់ថាបង្កានមិនមែនជាមនុស្សគ្គកលីលាទេ ។

ទីនមិនហួសបីគបក្លាយ :

– មែនហើយ ។  វាជាមនុស្សចិត្តល្អកម្របរកបាន,   រីមនុស្សណាដែលចិត្តល្អដូច
សុទ្ធតែឆ្កួត ត្រូវស្លាប់ពោលជាដាច់ខាត! ហ៊ឺះ ប្រើស្មៅគ្រញ៉ាំខ្លាចាប់ដីតបខ្នង,   ស្មៀតបេះ
ពោលស្មៅចាប់ដីតបចង្កេះ!   កលល្បិចនេះល្អណាស់! ប្រសប់ណាស់! ល្អទៅប្រើ!

សំដីនេះលាន់ឮដល់ត្រចៀកស៊ីផានមិនទីនគុន បណ្តាលឲ្យអ្នកចាំងពីរនាក់ត្រឹតគិតថា លោកតា
ដឹងល្បិចកិច្ចកលខ្លួនអស់ហើយ ។ ស៊ីផានឥតភ័យប៉ុន្មានទេ, ទីនគុនភ័យស្លន់បែកញើសជោគទឹកជា:

–លោកតាដឹងរឿងជាមុនប្រហែលគាត់ប្រុងប្រយ័ត្នណាស់,   បង្កានមិនវាយប្រហារគាត់
យល់ថាល្អឬអាក្រក់ហ្ន៎ ?

ស៊ីផានដូចជាល្ងង់ដែរ  នាយមិនព្រមជឿថាថ្ងៃស្អែកទីនបិនហួសបីស្លាប់នាយទេទេ ដូចពាក្យ
សន្យាឡើយ  ។  មិនយូរប៉ុន្មាននាយដេកលក់ទៅ . . .

នៅពេលភ្លឺស្រាងៗនាយត្រសម្លឹងឡូឡានៅមាត់ប្រាំង  ។  ខ្លះស្រែកថានៅត្រង់នេះហើយ
ខ្លះថាតិចូកហ្នឹងឯង,   ខ្លះដេរថាកុំបណ្តោយឲ្យព្រាយបិសាចនេះរត់រួចឡើយ!

មាណពក្រោកអង្គុយភ្លេតក្រឡេកទៅមើលគេឃើញមនុស្សកាន់ចង្កៀងរត់តម្រង់មក ។ ផងប្អូន
ប្រាំនាក់ចុះដល់ក្បាលទូកមុនស្រែកសន្ធាប់!

– បិសាចទៅណាហើយ! កុំឲ្យបិសាចរត់រួចគេឃើញ!

ទីងមិនហួសប៊ីស្ទុះចេញមកស្រែកសួរ :

-ពួកឯងជាអ្វី, បានជាហ៊ានរំខានដំណេកយើង ?

បុរសម្នាក់បន្ទុលគាត់ស្រែក:

- ចេញមកហើយ ។... ឆាប់បាញ់ភ្លាម !

បុរសពីរនាក់ឈរក្បែរនោះ ដែលកាន់បំពង់កំលើកបាញ់ភ្លាមៗ តម្រង់ទីងមិនហួសប៊ី ។ គឺជាឈាមក្រហមច្រាល, ឯមនុស្សមួយក្រុមនៅលើគោកស្រែកហ៊ោកញ្ជ្រៀវ :

- ឈាមខ្មៅស្រោចស្រប់លើព្រាយបិសាចហើយ ! វាត់ទៅណាមិនរួចទេ !

ប៉ុន្តែឈាមដែលបាញ់ទាំងប៉ុន្មានឥតប៉ះ ប្លុងទឹកទីងមិនហួសប៊ីមួយតំណក់ឡើយ, ព្រោះគាត់ទន្ទ្រាំជើងហោតខ្ពស់ផុតស្រែកទាំងក្តៅក្រហាយ :

-ពួកឯងពល់គ្នាមកពីទិសណា បានជាហ៊ានយកឈាមខ្មៅមកបាចសាចយើង ហើយចោទយើងជាព្រាយបិសាចហ: ?

ធម្មតាទីងមិនហួសប៊ីសម្លាប់មនុស្សឥតញញើតដៃទេ ឲ្យតែមិនសប្បាយចិត្តម្ដងៗគាត់សម្លាប់ហើយ ទោះគេមិនរំខានគាត់ក៏ដោយ ។

ពេលនេះ មិនត្រឹមតែរំខានដំណេក គេហ៊ានប្រមាថគាត់ទានគាត់ដល់កន្ទេង ទីងមិនហួសប៊ីខឹងណាស់ទាល់តែជើងទាំងពីរត្រូវអ្នកកាន់បំពង់ទឹងផងម្នាក់ឈរមុខគេខ្ទាតប៉ុនដូចស្លឹកកណ្ដាប ។ អ្នកទាំងពីរគ្មានគុនវិជ្ជាអ្វីសោះ មកត្រូវកម្លាំងកាយទីងមិនហួសប៊ី ក្នុងពេលគាត់ខឹងទ្រាំទ្រឯណាបាន ពីរនាក់ដួលស្លាប់ទឹងកន្ទេងទន់ខ្លួនល្អក, ម្នាក់ទៀតប៉ុងលើអាកាស ធ្លាក់ស្ប៉ែកលើដីគោកស្លាប់ភ្លាម ។ ទីងមិនហួសប៊ីមិនទាន់អស់ចិត្ត គិតបង្វិលខ្លួនទៅលើគោកវាយសម្លាប់ឲ្យស្អុបដៃ ស្រាប់តែឮទីងគុងស្រែកពីក្រោយ:

- លោកតា, មួយថ្ងៃមិនដែលហួសប៊ី !

ទីងមិនហួសប៊ីស្រឡាំងកាំង ឈឺញើរពុកមាត់ពុកចង្កា ។ ដោយកំណាចខឹងខ្លាំងពេកគាត់ភ្លេចពាក្យបណ្ដាំរបស់លើង ។ ពេលនេះឮចៅប្រុសពុកគាត់ចិចប់ចិត្តឈរស្ងៀម ។ ជននៅលើគោកទាំងអស់ភ័យលោះព្រលឹងស្រែកឡើងខ្វា :

- បិសាចកាចណាស់ហ្វឹយ ! ឆាប់រត់គេចខ្លួនយើង ! រត់...

មួយរំពេចនោះគេតក្រណាត់ត្រណែងអស់ ហោលបន្ទៀនកក់ពាយពេញមាត់ប្រាំង និងសាកសពមួយ ។ ទីនមិនហួសបីគ្រះសពចាំងពីលើក្តារទូកម្ខាងហោលកូនចិក ហើយស្រែកប្រាប់អ្នកចែវទូក :

-ចេញដំណើរភ្លាមឡើង ! បើមានមនុស្សមកទៀត យើងសម្លាប់លែងបានហើយ !

តាចាស់ចែវទូកភ័យទន់ដៃទន់ជើង ចាប់ច្រវាចែវផាប់ ។ ទីនមិនហួសបី ចាប់ឬស្សីខ្លួនឯង ពោលទូកតូចឲ្យចេញពីមាត់ប្រាំងយ៉ាងរហ័ស ។ ក្លិនឈាមនៃក្តប្រឡាក់ពេញទូកផ្សំក្លិនផ្កាបណ្តូល ផ្លូលប្រមុះ ។

ទីនមិនហួសបីងាកសួរទៅស្រីដោយទឹកមុខមាំ :

-កញ្ញា ! នេះជាកលល្បិចរបស់ឯងទៀតហើយមែនទេ ? ហេតុអី ?

ទីនគុនសើចស្រស់សួរដីកា :

-លោកតាៗ, សំដីលោកតាទៀងទាត់ទេ ។

-អ្នកណា ហ៊ានថាសំដីតាមិនទៀងទាត់ ?

-ល្អណាស់! លោកតាក៏ណាត់ពេលឲ្យបងឆានដប់ថ្ងៃដើម្បីរាយប៉ាយរាន់ផានឲ្យឈ្នះ បើមិនកើតការទេលោកតាសម្លាប់គាត់ចោល ។ ថ្ងៃនេះជាថ្ងៃទីដប់តែលោកតាសម្លាប់មនុស្សគ្រប់ចំនួនហើយណា !

ទីនមិនហួសបីក្រាក់ក្រើតស្រែកទាំងកំហឹង :

- មីចៅចង្រៃមានកលល្បិចច្រើនសន្ធឹកណាស់ , តាបាញ់ប្រាកឯងស្រឡះហើយម្តងហ្នឹង !

ទីនគុនពោលទាំងញញឹម :

-សំដីលោកតាត្រកូលទីនជាពាក្យសច្ចៈ លោកថាថ្ងៃគំរប់ដប់ត្រូវសម្លាប់បងឆានចោល ។ ប៉ុន្តែ បើគិតតាមហេតុនាម „ទីនមិនហួសបី„ លោកតាសម្លាប់មនុស្សគ្រប់ចំនួនហើយ , មិនអាច សម្លាប់ផងទីបួនបានទេ ។ នុំ ! លោកតាអើយ ! បើថ្ងៃនេះលោកតាសម្លាប់គាត់មិនបានថ្ងៃស្អែក ក៏តាមិនត្រូវសម្លាប់បងឆានដែរ ។ ក៏បខ្ញុំមើលទៅប្រសាទនេះ មិនមែនត្តជល្អទេ ។ ចាំមើលតែគាត់ជាមែនទែន គាត់នឹកឃើញយុទ្ធសិល្ប: ដែលរៀនចេះចាំប៉ុន្មានមកប្រើការវិញ លោកតាមិនបាក់មុខដោយសារគាត់ឡើយ ។

ទីនមិនហួសបីទឹងណាស់ខ្ទន្លាំផើងផាំងៗ បាក់ក្តារទូកប្រាវហើយស្រែក:

- មិនបានទេ ។ ទីងមិនហួសបីទាញកលឲ្យបាយមិនប្រមក់ឯងនេះ រឹតតែកម៉ាស់មុខទៅទៀត ។

ទីងតុងសើចក្អាកក្អាយៈ

- ខ្មាសឯណា ? ខ្ញុំផាប់ស្រីទៅផាមួយលោកតាយូហើយតើ ។ ខ្ញុំសន្យាថាមិននិយាយរឿងហ្នឹងប្រាប់អ្នកដទៃទេ ៗ

ទីងមិនហួសបីស្រែកឡូៗៈ

- តាទាញកលទៅហើយ តាមិនសប្បាយចិត្តទេ, ទៅទៅនិយាយប្រាប់អ្នកណាក៏បានដែរ, តាមិនឈឺក្បាលទេឿយ ៗ

សុីផានសម្ងំស្ដាប់ជីតានិងទៅដៃកគ្នាមួយសន្ទុះនេះទាយយល់ដោយឆាយថាទីងតុងទៅសុំបករាលអ្នកស្រុកឲ្យរកគូនជីតាដើម្បីឲ្យទីងមិនហួសបីសម្លាប់មនុស្សគ្រប់ចំនួនតាមពាក្យសន្យា ដែលហោរាបង្គាប់ព្រួសា ៗ នាយពោលថាៈ

- ទីងៗតុងៗ គ្រាន់តែចង់ជួយខ្ញុំប៉ុណ្ណឹងធ្វើបាបគេទាល់តែស្លាប់អស់បីនាក់ឥតប្រយោជន៍ ... ធ្វើដូច្នេះឃោរឃៅណាស់ ៗ

ទីងតុងផ្ទាះទឹកមុខសួរថា :

-ម៉េចបងបន្ទោសខ្ញុំទៅវិញ?

មាណពស្រឡាំងកាំងពោលមិនចេញ, ទីងតុងពោលបន្តៈ

-បងទេតើដែលឃោរឃៅនោះ! ទឹកចូលដល់ច្រមុះហើយការស័យតែគិតមុខគិតក្រោយខ្វាញញ៉ើញញ៉ា, បើព្រមធ្វើតាមខ្ញុំ, យើងរត់ដល់ព្រៃប្រៅតួនបាត់ហើយមិនចាំបាច់សម្លាប់មនុស្សបីនាក់ទេ ៗ

មាណពគេពាក្យឆ្លើយមិនរួចក៏នៅស្ងៀម ៗ ខណៈនោះទីងមិនហួសបីសើចហាសៗ ពោលពន្លឺឲ្យមក :

- បានហើយ ៗ ! អាចំកួតក្រកូលសុីអើយ ! តាគ្រាន់តែខ្វះគ្រាប់ភ្នែកឯងមួយគូ និងកាប់ដៃពាំងពីរទោលអស់ទៅវាប្រែចយ៉ូងទៅហើយ ៗ ឯងមានស្លាប់ឯណា គ្រាន់តែក្លាយជាជនពិការៗ ម៉ែបៅ ! បើតាមិនសម្លាប់វាឯងថាខុសពាក្យសំបថមួយថ្ងៃមិនហួសបីដែរឬ ?

សុីផានទិនទីងតុងភ្ញាក់ផ្ញើបគេគន្ទ្រាក់ ៗ ទីងមិនហួសបីរឹតតែសប្បាយសើចខ្លាំងទៀត :

-អស្ចារ្យ! យើងគិតត្រូវមែន! មិនសម្លាប់អ្នកចំប្អូនទេ, គ្រាន់តែខ្ទេះភ្នែកនិងកាប់ដៃឲ្យក្លាយ
មនុស្សក្អួតពិការ ... ហាស ! ...

ចិនតុងរកពាក្យឆ្លើយមិនបានក៏តវ៉ា :

-កុំប្រញាប់ពេកលោកតា ! មិនទាន់ផុតកំណត់ទេ ។ ក្រែងបន្តិចទៀតបងជាន់យើ
ប៉ាយកាន់ជាងគាត់វាយឈ្នះណា! យើងកុំអាលទាយមុន ។

ចិនមិនហួសបំភ្លាយសំណើចក្អាកក្អាយ :

- មែនហើយចៅស្រី ! តាមិនបេះគូតកុហកឬរលោកគ្នាឯងទេ ។ តាងំចាំផលយាមបីយប់
នេះទើបសម្លាប់វា ។

ម្តងនេះចិនតុងព្រួយលើសមុន ព្រោះនាងរកមធ្យោបាយជួយស៊ីផានមិនបាន ។ ចំណែ
មាណពឥតដឹងគ្រោះថ្នាក់ជិតបង្កើយទេ, ឃើញនាងក្រមុំធ្វើមុខជូរនាយសួរ :

- ចិន ៗ តុង ៗ ម៉េចធ្វើមុខអីចឹង ? មានការអ្វីទៀតឬ ?

ចិនតុងខឹងណាស់បន្ទោស :

- បងមិនឮលោកតាមានប្រសាសន៍ទេឬ ? គាត់ខ្ទេះគ្រាប់ភ្នែកបងហើយកាប់ដៃចោលទៀតណា
ស៊ីផានបែរជាសើចធ្វើព្រងើយ:

-លោកតាបំភ័យយើងលេងទេតើ ! នាងកុំជឿ ! គាត់យកគ្រាប់ភ្នែកនិងដៃខ្ញុំទៅធ្វើអីកើត !

ចិនតុងខឹងណែនបំពង់កនឹកថា :

- គាត់នេះនិយាយផ្តេសផ្តាស ហើយល្ងង់ខ្លៅណាស់, យើងនៅជាមួយមិនបានយូរ
ព្រោះព្រួងស្លាប់មិនខាន ។ លោកតាចង់សម្លាប់គាត់ឬ ? ណ្ហើយ ! ឲ្យគាត់ស្លាប់ទៅចុះ
បើលោកតាគ្រាន់តែខ្ទេះភ្នែកនិងកាប់ដៃគាត់, គាត់ក្លាយជាជនពិការ, តើយើងទទួលមនុស្សពិការធ្វើប្តីបា
ដែរឬ ? ពិការហើយល្ងីល្ងើទៀតលោកអើយពិបាកគិតណាស់ ។

ព្រះអាទិត្យចាំងរស្មីលើផ្ទៃទឹកតែប្រជែងជាមួយរលកចាំងភ្នែកព្រិច ៗ ។ ថ្ងៃរះខ្ពស់ឡើ
កាលណាចិនតុងតប់ប្រមល់ខ្វល់ខ្វាយកាលនោះ ។ នាងសញ្ជឹងគិតម្តងទៀត:

- បងជានជាមនុស្សល្អសោះ លោកតារកធ្វើបាបគាត់ ខ្ទេះភ្នែកគាត់ .... អើ ! ចុះធ្វើអីកើ
មនុស្សអីចឹង ? សម្លាប់ចោលផ្ទាល់ដៃវិញប្រសើរជាង ។

## វគ្គទី ១៧

## បងប្អូនត្រកូលឌឹង

ពេលនេះចិនតុនឈរសម្ងំមើលស៊ីផានពីក្រោយខ្ទមមួយសន្ទុះ ទើបដាច់ចិត្តខាំមាត់លូកដៃចាប់ដំបងនាយភ្លាម ។ នាងប្រើដៃស្ដាំតាមស្នៀតក្រញាំខ្លាចាប់ដំបងលើខ្នង, ដៃឆ្វេងប្រើស្នៀតបេះផ្កាបោលស្ទាវគៀបដំបងលើចង្កេះ ។ មាណពផតប្រុងខ្លួនបន្តិចសោះនោះ ក៏ចង់ខ្លួនកំរើកលែងរួច ។ ចិនតុនក៏ត្រូវកប្បាំងកាតុបាណពបណ្ដាញខ្លាតវិះឆ្មាត់ចំកដែរ, តែនាងហើសចាប់តែមខ្លួកដាប់ស្រែកជៀលថា:

–លោកតាចង់ទេះត្រាប់ក្អែកបង, ចង់កាប់ដៃបងទៀតមនុស្សពិការបែបហ្នឹង មិនគ្រឹមអាប់មុខមាត់លោកតាទេ, ចិនតុនខ្ញុំក៏ខ្មាសគេដែរ ។ ផ្ទុយវិញទៅឲ្យលោកតាធ្វើទេ, ខ្ញុំក៏ទេះក្អែកបងឯងដែរ !

ពេលហើយនាងស្រាយខ្សែខ្លួកមកចងដៃបងជើងមាណពដាប់ សល់ពីនោះនាងក៏ស្រាក់នាយតាំងពីស្មាដល់ជើងដូចគេរុំនំអន្សម ។ ស្នៀតចុចដំបងនេះត្រូវតាំងមាត់ចំនួនមួយម៉ោងទើបនិយាយផតរួច ។ ប៉ុន្តែស៊ីផានមានកម្លាំងជ្រៅជ្រះអាចនិយាយបានដូចធម្មតា ។ នាយសួរថា:

–ចិនៗតុនៗ ធ្វើលេងឬ ?

លុះក្រឡេកឃើញមុខចិនតុនកាចសាហាវខុសពីធម្មតា នាយផ្លាស់ទឹកមុខគួរឲ្យអាណិតវិញ ។ ចិនតុនលើកជើងធាក់នាយម្ដងស្រែកថា :

–ហ៊ឹះ! ជិតស្លាប់ហើយនៅយល់សប្តិចាំងស្រស់ទៀតឬ? ខ្ញុំមិនបេះលេងជាមួយមនុស្សភ្លីភ្លើដូចឯងទេ! ចុកបងឯងរស់នាំធ្ងន់ផែនដី, ខ្ញុំសម្លាប់ចោលហើយ ។

ពោលចប់នាងហូតកាំបិតខ្លាកក្រវាសក្រវាត់ពីមុខនាយដូចគេសំលៀងកាំបិត ។ ស៊ីផានភ័យណាស់ពោលអង្វរ :

– ចិនៗ តុនៗ កុំសម្លាប់ខ្ញុំអី ! ចាប់ពីថ្ងៃនេះទៅខ្ញុំស្ដាប់បង្គាប់នាងទាំងអស់ ។

– ហ៊ឹះ ! ខ្ញុំចង់ជួយបងឯងឲ្យគង់ជីវិតដែរ តែបងមិនព្រមតាមខ្ញុំសោះ នេះមិនដឹងបងចង់ស្លាប់ឬ ? កុំបន្ទោសអ្នកដទៃនោះ ! ពេលនេះបើខ្ញុំមិនសម្លាប់, បន្តិចទៀតលោកតាមកសម្លាប់ដដែលៗដដែល ។ ខ្ញុំត្រូវសម្លាប់ប្ដីខ្ញុំដោយផ្ទាល់, មិនឲ្យនរណាមកសម្លាប់ប្ដីខ្ញុំឡើយ ។ មិនបានសម្លាប់ផ្ទាល់ដៃចិនតុនឥតស្គាល់ការសប្បាយរីករាយដូចគេទេ ។

ស៊ីផានអង្វរទៀត:

-សូមនាងករុណាកុំប្តូរទៅ, ខ្ញុំឈប់ធ្វើប្តីនាងទៀតហើយ ។

-យើស! សំពះថ្មីមួយហើយ មិនធ្វើប្តីខ្ញុំបានឬ កុំនិយាយច្រើនពេកប្រយ័ត្នខ្ញុំកាប់ក្បាលទម្លាក់ចោលក្នុងទឹកទន្លេណា!

មាណពភ័យស្លុតលែងហ៊ានអង្វរ, ចិនមិនហួសប៊ីសើចហាស ៗ:

- ល្អ! ល្អ! នេះបានសមធ្វើទៅស្រីចិនមិនហួសប៊ី! សម្ទុះអាចោលទៅនៅចាំដល់ណាទៀត!

ចំណែកតាចាស់កាន់បង្កួតទូក គាត់ភ័យញញើញញ័រកាច់បង្កួតលែងត្រង់ទៅហើយ ។ ឃើញចិនគុនកាន់កាំបិតប្រុងប្រៀបសម្លាប់ប្តី គាត់បែរទូកខុសផ្លូវស្រេច ។ ពេលនោះមានទូកតូចមួយទៀតលឿនស្ទើរ មកពីមុខបៀសគ្នាមិនផុតទេ ច្បាស់ជាប៉ះទង្គិចមិនខាន ។ អ្នកកាច់បង្កួតទូកមួយនោះស្រែកភ្ញាក់សំឡេងទំកាច់បង្កួតចាំងភ័យស្ទុះ ។ ចិនគុនលើកកាំបិតលើផ្ទៃមុខស៊ីផានចាំងស្មើព្រិលភ្លែក ។ ចិនគុនធ្លាក់វាងវៃណាស់ នាងបុកកាំបិតឈិបប្រផិតក្បាលមាណពហើយលោសដៃលើកខ្លួនមាណពបោះទៅផ្ទះក្តារលើទូកមួយទៀត ដែលមកដល់ទង្គិចគ្នាយ៉ាងហើស ។

ចិនមិនហួសប៊ីភ្ញាក់ព្រើតទំងណាស់ហើយចាញ់កលបៅស្រីផាលើកទីពីរ ។ គាត់ស្រែកគំហក:

-ឯង ... ឯងធ្វើម៉េចហ្នឹង?

ព្រមទាំងស្ទុះក្រវីក្រវាមកក្រៅ តែទូកតូចទាំងពីរឃ្លាតពីគ្នាប្រហែលដប់ម៉ែត្រស្រេច ព្រោះទឹកហូរខ្លាំងពេក ។ ទុកជាចិនមិនហួសប៊ីចេះសំកាលខ្លួនក្បែរយ៉ាងណាក៏មិនអាចលោតដល់ទូកមួយនោះដែរ គាត់យកដៃទះកំភ្លៀនចិនគុនផាំង ហើយស្រែកបញ្ជា:

-ចាប់ ... ចាប់បតទូកដេញតាមភ្លាម!

ប៉ុន្តែទឹកទន្លេឈាងការត្រង់កន្លែងនេះហូរខ្លាំងណាស់ មិនអាចបត់ក្បាលទូកបានឆាប់ ៗ ទេ ។ ម៉្យាងទៀតកូនទូកមួយនោះទៅហួសផុតកន្ទុយភ្នែកផង ដែបដេញមិនទាន់ទេ ។

រីឯងពីស៊ីផានដែលបិទភ្នែករង់ចាំមច្ចុរាជ ហើយស្រាប់តែនាងចិនគុនលើកបោះទៅក្នុងទូកមួយទៀត ។ នាយចាប់អារម្មណ៍ហាក់វិលក្នុងលំហអាកាសមួយថ្លុំ ទើបធ្លាក់ផ្កាប់មុខលើវត្ថុអ្វីមួយទន់ល្មើយឥតឈឺសោះ ហើយមើលមិនឃើញច្បាស់ទៀត ឮតែសម្លេងស្រែកតិច ៗ ។ នាយមើល

មិនឃើញ ហើយហាមាត់និយាយមិនរួច តែពុំភ្លេចក្រអូបឈ្ងុយឈ្ងប់ដូចកាលនាយដេកលើគ្រែខ្នើយ ល្មើយនៅក្នុងបន្ទប់របស់ក្រមុំឈានល្អ ។

មួយរយៈពេលដ៏ខ្លីទើបនាយស្មានស្មារតីដឹងថា ដេកផ្កាប់មុខលើពូក ក្បាលលិចក្នុងខ្នើយដ៏ធំទន់ បានជាកំរើក ឬងាកក៏ហាមាត់និយាយមិនកើត ។ ជាពិសេសគឺនាយទើសនឹងក្បាលមួយទៀត លើខ្នើយជាមួយគ្នា មានសក់វែងរវាត់រាយ ពាសពេញលើខ្នើយ ។ ស៊ីផានភ្ញាក់ក្រញាង ដោយដឹងច្បាស់ជាមនុស្សស្រី ។ នាយស្រែក អូ ! តែមិនចេញសម្លេងមកក្រៅសោះ ។ ភ្លាម នោះមានដៃមួយលូកមកក្របួចករអាវនាយ ហើយវត្ថុម្យ៉ាងត្រជាក់ស្រឹបប៉ះបំពង់កភ្លាម ។ សម្លេង នារីស្រួយស្រោកបន្ទឹថា:

-ឯងជាអ្នកណា? ឯង... ជាកូនចៅរបស់កញ្ចាស់ចិនមិនហួសបួនឬ ?

ស៊ីផានដឹងថាគេផ្កាប់កាំបិតកំញើញហើយក៏ខំជាវដេក ។ នាយនិយាយបានតែខ្ញុំ ... ខ្ញុំ ... នារីនោះគំហកទៀត :

-ឯងលបចូលក្នុងទូកយើងបែបនេះមិនមែនជាមនុស្សល្អទេ ។ ខ្ញុំសម្លាប់ឯងចោលឥឡូវហើយ ។ ពោលផងគេប្រឹងសង្កត់កាំបិតថែមទៀតផង ។ ស៊ីផានឈឺណាស់ស្រែកខ្លាំងៗ :

-ខ្ញុំឥតលួចចូលមកទេ, មានមនុស្សបោះខ្ញុំចូលមកតើ !

នារីពោលទាំងភិតភ័យ :

- នែ...ចាប់ចេញមក ! ឯង . មើបរបៀបចូលក្នុងជួយខ្ញុំអីចឹង ?

មាណពភ្ញាក់ក្រញាងដឹងច្បាស់ថា នៅក្រោមពោះមានពូក , នៅក្រោមមុខនាយគឺខ្នើយទន់ ល្មើយហើយនៅលើខ្នងមានខ្លួយមួយជាន់គ្របពីលើទៀត យ៉ាងនេះហើយបានជានាយកក់ក្ដៅម្ល៉េះ ។ ព្រោះចិនកុនបោះនាយចូលក្នុងកូនទូកនេះតាមបង្អួច ជាកន្លែងដេកនៃនារីម្នាក់មានពូកខ្ពស់ខ្នើយតែប្ដូរ ។ បើចិនកុនមិនចុចជីតចរហើយមិនងចរាំវដ្ឋបនិអន្សមនាយក្រោករត់ផុតទៅហើយ ។ ពេលនេះ នាយកំរើកម្រាមដៃមួយក៏មិនរួចដែរ ទើបឆ្លើយប្រាប់គេថា :

- ខ្ញុំកំរើកមិនរួចទេ , សុំនាងជួយទាញខ្ញុំចេញពីនេះផង, ខ្ញុំអង្វរ ។ នាងចង់ទាត់ប្ដូណាក់ ក៏ខ្ញុំព្រមដែរ ឲ្យតែចេញផុតពីកន្លែងនេះ ។

នាយពោលសឹងមិនចប់ស្រាប់តែឮសម្លេងយាយចាស់ម្នាក់ពោលកាត់:

- ឲ្យអារំបល់យកនេះនិយាយធ្វើអី, ឆាប់សម្លាប់វាទៅ ។

នារីតប:

- លោកយាយ, បើសម្លាប់គាត់ទៅ ខ្ញុំ . . . ខ្ញុំច្បាស់ជាប្រឡាក់ឈាមពេញខ្លួនហើយ ។ ធ្វើយ៉ាងម៉េច . .

នារីពោលដាច់ៗ ដោយភិតភ័យ, ដូនចាស់គំហក :

- អាញ្ចឹងជាស្អី ? មកពីណា ? នែអារំបល់យកចេញមក!

ស៊ីផានតបពីក្នុងផ្លូយ ;

-លោកយាយអើយ ខ្ញុំកម្រើកឥតរួចទេ, លោកយាយមកមើលចុះ គេចងជើងចងខ្ញុំត្រង់ខ្នង និង ចង្កេះ ហើយគេរុំបន្ថែមដូចគ្នាទៀតកម្រើកមិនរួចទេ ។ សូមអ្នកស្រីខាងណោះក្រោកឡើង យើងដេកក្នុងផ្លូយតែមួយអ៊ីចឹង នែ.. នែ ... មិនស្រួលទេ ។

នារីគំហក :

- អ្នកស្រីស្អី ? ខ្ញុំជាអ្នកនាងណា ! ខ្ញុំក៏កំរើកមិនរួចដែរ ។ លោកយាយអ្ហា ! ឆាប់ . . . រកមធ្យោបាយដោះស្រាយរឿងនេះផង ។ គាត់នេះកំរើកមិនរួចមែន, គេចងស្រាក់គាត់ច្រើនកំណាត់ណាស់ ។

ស៊ីផានពោលបន្ត:

- លោកយាយ, ខ្ញុំសុំអង្វរ . . . លោកយាយករុណាទាញខ្ញុំចេញទៅផង ! ខ្ញុំធ្វើខុសត្រង់ណា សូមអ្នកនាង . . . មេត្តាអភ័យទោសផង ។

ដូនចាស់គំហកថែម:

- យើ អាកំហូច ! ហ៊ាននិយាយចំអកផងឬ ?

នារីឲ្យយោបល់ :

- លោកយាយ, យើងហៅតាចាស់កាន់ចង្កូតទូកមកជួយទាញគាត់ចេញបានទេ ?

-មិនបានទេ ! ហ៊ានឲ្យអ្នកក្រៅចូលក្នុងទូកនេះមួយជំហាន យើងពីរនាក់ច្បាស់ជាស្លាប់ ។

មាណពនឹកថា ប្រហែលជីដូនជិនចៅនេះត្រូវគេចងក្រៀកកំរើកខ្លួនមិនរួចដែរឬ ?

ដូនចាស់ខឹងផងអន្ទះអន្ទែងផង ស្រែកគំហកទៀត :

-អាកំហូច ! អាចំកួត ! ខ្ញុំកឯទៀតមើចឯងមិនទៅ, ចង់មកជិះតែខ្លួនអញ? អាស៊ីវ! សម្លាប់ក្រាមទៅប្រឡាក់ជួយក៏មិនអីដែរ ។ អានេះគង់តែស្លាប់ទេបើមិនយូរក៏ឆាប់...

ស៊ីផុតានប្រញាប់ស្រែកខ្លាំង ៗ :

- សម្លាប់មិនបានទេ ! ឈាមអាក្រក់ណាស់ប្រឡាក់ជួយខ្លួនអស់លែងក្រអូបទៀតណា ! ម៉្យាងទៀត. .នែ... ម៉្យាងទៀតសម្លាប់មនុស្សក្នុងជួយមិនមែនស្រួលទេ ។

នារីលាន់មាត់អូយ! លើកកាំបិតចេញពីបំពង់កនាយក្លាម ។ មាណពគ្រេកអរណាស់និកថានាងនេះប្រហែលនៅក្មេងខ្លាចណាស់ទើបបន្តថា :

-នាងកុំចង់សម្លាប់ខ្ញុំណា! ពេលនេះខ្ញុំកើតមិនរួចមែនដល់សម្លាប់ខ្ញុំទៅ ខ្ញុំក្លាយជាខ្មោចទៅដេកជិតនាង,នាងមិនខ្លាចទេឬ? កាលណាស្លាប់ខ្ញុំកើតដៃជើងបានហើយ តែខ្មោចត្រជាក់ស្រិបដូចទឹកកក ។ ខ្ញុំចាប់ប្រចាប់កនាង ...

នារីភ័យខ្លាំងណាស់ ប្រញាប់ស្រែកកាត់:

- ខ្ញុំមិនសម្លាប់លោកទេ, មិនហ៊ានសម្លាប់ទេ ។

ស្មៀមមួយសន្ទុះ នាងពោល:

- លោកយាយ, គិតធ្វើយ៉ាងណាឲ្យគាត់ចេញទៅបាន ?

ដូនចាស់ឆ្លើយក្លាម :

-យាយកំពុងរកនឹកហើយ, ទៅកុំមាត់ !

ពេលនោះមេឃកាន់តែងងឹត, នៅក្នុងខ្ទមមើលគ្នាមិនឃើញទេ ។ ស៊ីផុតានដេកទន្ទឹមគ្នាជាមួយនារីនោះក្នុងជួយតែមួយទៀត ។ ចិត្តក្តៅក្រពុំតែបោះនាយមកណាស់បានជាមិនប៉ះខ្លួននាងនេះបន្តិចសោះ ។ ឥឡូវមាណពព្រឺងឡើមនាងញាប់ញ័រខ្លួនដូចជាភ័យតក់ស្លុត, ទឹកនំកើបណាស់ ។ អស់រយៈពេលយ៉ាងយូរ ដូនចាស់ក៏រកមធ្យោបាយមិនឃើញសោះ ។ ក្នុងសភាពដ៏ស្ងាត់ជ្រងំនៃរាត្រីស្ងាត់ ស្រាប់តែព្រុសម្ល៉េងហួចខ្ទរក្លួរឲ្យស្រៀវស្រើប រួចព្រុសំណើចហាស ៗ ញ្ញាប់ផ្អើល, ជាសំណើចមនុស្សចាស់ពិតប្រាកដ ។ បន្ទាប់មកទៀត ព្រុសម្ល៉េងស្រែកសួរ :

- អីអាល្អួយ ! ខ្ញុំចាំឯងមួយយប់មួយថ្ងៃហើយ, ម៉េចក៏យូរម្ល៉េះ? ល្ងោះពេលទើបមកដល់ ។

នារីភ័យស្លន់ ស្លោដើដូនញ័រ ៗ :

- យាយអើយយាយ ! កញ្ចាស់នោះមកតាមយើងទៀតហើយ, គិតយ៉ាងម៉េចទៅ ?

ដូនចាស់ធ្វើហ៊ឹះ ឆ្លើយ :

- ទៅកុំអាលមាត់, យាយសម្ងំចាំមើលកម្លាំងតាតុ ហើយក្រែងកំរើកបាន យាយលោតក្នុងទឹកស្ទឹង សម្លាប់ខ្លួនតែម្ដង កុំឲ្យកញ្ចាស់នោះធ្វើបាបបាន ។

នារីប្រកែកញាប់មាត់:

- លោកយាយ, មិនបានទេ ។ . .

យាយចាស់ស្រែកគំហក:

- ថាកុំឲ្យរំខានយាយទៀត ឯងស្ដាប់បានទេ ? បើយាយលោតទឹក, ទៅទៅតាមយាយដែរ ?

នារីរុញរាបន្តិចទើបឆ្លើយ:

- ខ្ញុំសុខចិត្តស្លាប់ជាមួយយាយហើយ !

ដូនចាស់សរសើរថាល្អមួយម៉ាត់ ហើយឈប់ស្ងៀម ។

ស៊ីផាននឹងល់ណាស់ដណ្ដឹងសួរថា ហេតុអីបានជាជីដូននិងចៅកំរើកមិនរួចដែរ ? ហើយសីយសៀវ អ្វីសត្រូវដេញតាមទាន់ទៀត ? ពិតជាពិបាកគិតមែន !

ពេលនោះឮសម្លេង « កញ្ចាស់ » ស្រែកមកទៀត :

- ម្ដងនេះចង់កាប់វាវក៏បាន, គុនប្រវាល់ក៏បានទៀត ! ចង់មិនហួសពួនសុខចិត្តកំដររហូត ! លើកនេះគិតប្រកួតគ្នាឲ្យបានបីយប់បីថ្ងៃទើបក្ដែត ។ អីអាណួនម៉េចមិនឆ្លើយនឹងយើងផង ?

មួយភ្លែតសោះសត្រូវតាមដល់ទូកស្រេច ។ ស៊ីផានឮគេស្រាវប្រវ៉ាក់ដែកក៏វ៉ាវរួចឮផ្ទាប់ ! ដូចមានវត្ថុអ្វីធ្លាក់លើក្ដារទូកបណ្ដាលឲ្យយោងយោងមួយខណៈ ។ គឺតាចាស់ដែលជិះទូកមួយនោះ បោះយុថ្កាថ្កក់ជាប់ទូកជីដូននិងចៅស្រី ។ តាចាស់កាន់បង្គិតស្រែកសួរ:

- អេ . . . នែ . . . ពួកឯងធ្វើអីហ្នឹង ?

ពេលនេះទូកផ្អៀងទៅឆ្វេងទៅស្ដាំយ៉ាងខ្លាំងហើយរហ័សបណ្ដាលឲ្យមាណពត្រឡប់ផ្កាប់ ពោះវិញ ហើយនារីផ្អៀងយកប៉ះនាយក្បាម ។ ស៊ីផានក្ដាក់ព្រើតស្រែកសួរ :

- យីនាង ! ម៉េចក៏ . . . នាង . .

នាយក្មាក់ព្រើតឈប់និយាយគ ព្រោះឃើញច្បាស់ថានារីកំរើកមិនរួចដែរ ។ បន្ទាប់ពីនេះ ក្បាលខ្លួកលិចបន្តិចក្នុងទឹក ព្រោះមានមនុស្សហក់មកឈរ ។ គឺតាចាស់ម្ចាស់សំឡេងនោះឯង ។ គាត់ពោលៈ

- អាល្ងួយ ! យើងមកដល់ហើយ ។ ប្រកួតគ្នាម្ដងទៀតឬ?

តាចាស់កាច់បង្កួតផ្អាកទៅស្រែកទៀតៈ

- នែឯងចង់យ៉ាងម៉េចហ្នឹង ? ខ្លួកបុកគ្នាលិចអស់ឥឡូវហើយ ។

តាចាស់មកដល់ថ្មីស្រែកតបទៅវិញ :

- រកក្លួសនេះបិទមាត់ឲ្យជិតទៅ ។

ស្រែកហើយតាចាស់លើកយុថ្កាបោះទៅខាងណោះប្រុងបែកទឹកសំពោង ។ ខ្លួកទាំងពីរបែកឃ្លាតពីគ្នាអណ្ដែតតាមទឹកហូររលរល់ ។ តាចាស់កាន់បង្កួតឃើញបុរសចាស់ដូចគ្នាលើកយុថ្កាបោះចុះបោះឡើងដូចដុំឈើកំលៀនអណ្ដែតគោកស្ងប់ស្ងៀមលែងនិយាយស្ដី ។

តាចាស់ឈ្មោះទីងសើចហាស ៗ ពោលថា :

-អាល្ងួយ ! យើងចាំឯងខាងក្បាលខ្លួកឯកេះនៃ ! យើងមិនចាញ់បោកឯងចូលទៅដើរខ្លួនទោសក្នុងខ្លួកទៀតទេ ។

ដូនចាស់ , ស៊ីផាននិងនារីឈ្មោះកេស៊ីតាក្រូនបន្តិចនឹកថាប៉េកញ្ជាក់នេះមិនហ៊ានចូលមកឃើញចំណាញពេលបន្តិចហើយ ។ មាណពនឹកទៀតថា ពន្យារពេលមកធ្វើអី? បើយាយចាស់ខំបម្រើនកម្លាំងកំរើកខ្លួនរួចគាត់នាំនារីនេះលោតទឹកទន្លេសម្លាប់ខ្លួនហើយ ។

នាយមិនដែលស្គាល់ពីដូននិងចៅពីរនាក់នេះទេ , ប៉ុ ១ នេះគេបបួលគ្នាសម្លាប់ , តែនាយមិនដាច់ចិត្តមើលគេស្លាប់ចំពោះមុខឡើយ ម៉្លោះហើយនាយខ្សឹបប្រាប់នាងថា:

- អ្នកនាង ១ . . . ជួយឃាត់លោកយាយកុំឲ្យលោតទឹកអី ។

នារីតបៈ

- គាត់ . . . មិនព្រមទេ ។ គាត់មុខផាលោតសម្លាប់ខ្លួនហើយ , ហ៊ឺ ... ហ៊ឺ ...

នាងខំអត់ធ្មត់ចុងប្រមុះយូរហើយ ពេលនេះទ្រាំមិនបាន ក៏ស្រក់ទឹកភ្នែកព្រោក ១ យំអណ្ដឹកអណ្ដក់ហៀរទឹកភ្នែកប្រឡាក់ដល់មុខស៊ីផាន ។ នាងពោលទាំងរាក់រអួលទៀតថា :

- សុំទោស ... ទឹកភ្នែកខ្ញុំប្រឡាក់លោកអស់ហើយ ។

ស៊ីផានមិនស្មានថានារីស្លូតបូតហើយបេះគួរសមបែបនេះទេ ព្រោះអម្បាញ់មិញនាងចង់សម្លាប់ខ្លួនទៅហើយ ។ ពេលនេះនាយផគផ្អើមធំពោលតប :

-អ្នកនាងកុំព្រួយ ទឹកភ្នែកបន្តិចបន្តួចប្រឡាក់ចុះ ។

នារីនៅតែយំ :

- តាមពិតខ្ញុំមិនចង់ស្លាប់ទេ, តែតាចាស់ដែលទើបមកដល់នេះ កាចសាហាវណាស់ ។ លោកយាយថាគាត់សុខចិត្តស្លាប់មិនឲ្យគញ្ចាស់នោះចាប់បានទេ ។ ខ្ញុំ.. ទឹកភ្នែកខ្ញុំប្រឡាក់លោកទៀតហើយ, សុំទោស...សុំលោកកុំខឹង ។ យី, មើចលោកយំដែរ ?

- ខ្ញុំឮនាងយំខ្ញុំស្រណោះណាស់ទ្រាំមិនបានក៏យំដែរណា !

ពេលនោះក្ដារទូកលាន់ប្រឹប ៗ ហើយឃើញស្រមោលមួយក្រោកអង្គុយឆ្ងក់ ។ មាណពមើលឃើញច្បាស់ជាដូនចាស់ចំរើនកម្លាំងកំរើកបានដូចប្រាថ្នា, នាយក៏យក្កុកក្ដាក់ពោលញ័រ ៗ ទៅកាន់នារី :

- អ្នកនាង.... អ្នកនាង.. លោកយាយក្រោកអង្គុយហើយ !

នារីលាន់មាត់យើ ! ប្រុងលូកដៃចាប់ទាញមាណពតែនាងកំរើកមិនបានសោះ ។ មាណពបើកភ្នែកក្រឡូងតាមមើលកាយវិការដូនចាស់ទៀតហើយពោលបន្ត :

- ទុះ ! គាត់លូកដៃមកទាញអ្នកនាង ។

នារីស្រែកស្ងូន :

-យាយ...កុំ...កុំចាប់ខ្ញុំ...ខ្ញុំខ្លាចណាស់ ។

ពេលនោះអាវនាងតឹងផ្អឹះដោយដូនចាស់លូកដៃពីរចាប់ទាញជាប់ ។ មាណពស្រែកឃាត់ :

- លោកយាយកុំចាប់គាត់ ។ អ្នកនាងមិនព្រមលោតទឹកសម្លាប់ខ្លួនតាមលោកយាយទេ ។ ជួយផង ! ជួយផង !

តាចាស់ឈ្មោះទីងឮសម្រែកមនុស្សប្រុសសួរដោយឆ្ងល់:

- អ្នកណាស្រែកឡូឡានៅក្នុងហ្នឹង ?

- ខ្ញុំ, លោកតាអើយចូលឆាប់មក, ចូលមក, លោកយាយមិនកាចរាយឈ្មោះលោកតា, គាត់

ប្រុងលោកគ្រូឯងទន់ទេហើយ, ជួយផង !

តាចាស់ភ្ញាក់ព្រើតយារដៃទះរួរ លើកដំបូលទូកមួយចំហៀង ហើយលូកដៃចាប់ដូនចាស់ជាប់ ៗ ដូនចាស់ខំប្រមូលកម្លាំងបានមកប៉ុន្មានត្រូវលាយរលាយអស់លើទង់ជើងជួលប្រុស ៗ តាចាស់ស្ទាបដីពប ស្ទាបខ្លួនដូនចាស់រួចស្រែកទាំងភ្ញាក់ព្រើត:

– អាល្អួយ ! ឯងហាក់ដូចជាខុសក្បួនខ្លាំងមែនទេ ? ម៉េចមិនប្រាប់គេឲ្យដឹងមុន, ខំអត់ទ្រាំយូរម្ល៉េះ ?

ដូនចាស់ដកដង្ហើមយូរ :

– លែងដៃចេញទៅ . . .កុំប៉ះយើង . . .ចេញឲ្យឆាប់ !

តាចាស់នៅតែបន្តថា :

– ដង្ហើមឯងដើរមិនដូចប្រក្រតីទេ ៗ មានគ្រោះថ្នាក់សម្បើមណាស់, បើមិនឆាប់ជួយ ប្រយ័ត្ន... ក្លាយជាមនុស្សពិការពាក់ ! ចាំយើងជួយឯង...

ដូនចាស់ស្រែកគំហក :

– ឯងកុំមកប៉ះយើងអ៊ីយ ! ទោះកើតមិនរួចក៏យើងអាចចាំអត្តភាពសម្រាប់ខ្លួនដែរ ៗ

តាចាស់ដឹងថាដូនចាស់ចិត្តក្ដៅមាត់រឹងណាស់, ថាយ៉ាងណាក៏ដូចយ៉ាងហ្នឹងហើយ ៗ គាត់ធ្វើមិនឮ ពោលត :

– សរសៃឈាមឯងរត់ខុសផ្លូវអស់ហើយ . . .

–ក្រែងឯងឈ្លោះយើងតាំងពីដើមមកឬ ? ឥឡូវយើងប្រទះគ្រោះថ្នាក់ឯងត្រូវសប្បាយ, ម៉េចក៏...

–ណ្ហើយស្ទះរឿងនេះទុកមួយអន្លើចុះ ៗ អាស៊ីវឯងយ៉ាងម៉េចដែរ ៗ ជួយអន្តរាយឯងផង ... យី ! ម៉េចក៏ចឹង ? អាស៊ីវ ... ឯងដេកជាមួយនរណា ? សង្សារថ្មី ?

អាស៊ីវនិងស៊ីផងនាំស្រែកដំណាលគ្នា :

– ទេ ៗ យើងកំរើកឥតរួចទៀយ ៗ

តាចាស់ឆ្ងល់ផងចង់សើចផង, លូកដៃចាប់តាញ៉ៅពកពៃដែលត្រូវចឹងគុំចងដូចនំអន្សមលើកផុតក្ដារទូកដូចគេលើកដុំឈើ បណ្ដាលឲ្យតាចាស់ភ្ញាក់ព្រើតពិនិត្យមើលសព្វគ្រប់ទើបសើចហាស ៗ:

–អាស៊ីវអើយ ! បុណ្យភ្ជុំបិណ្ឌកន្លងហួសទៅហើយ, ម៉េចឯងទំលាក់នំអន្សមគូនជួយធំម្ល៉េះ ?

អាស៊ីវប្រកែកញ៉ាញ :

-ទេ, គាត់ហាក់មកពីណា, ខ្ញុំឥតស្គាល់ទេ !

តាចាស់សួរទៀត :

– ចុះឯងកំរើកមិនរួចដោយសារអី, មិនមែនខំអន្សមទេឬ ?

ជូនចាស់ខឹងណាស់ស្រែកគាត់ :

– ឲ្យតែឯងហ៊ានប៉ះសរសៃសក់អាស៊ីវ, យើងប្តូរជីវិតនឹងឯងភ្លាម ៗ

តាចាស់ដកដង្ហើមធំ :

– បានហើយ ៗ ... យើងមិនតាល់វាទេ ៗ

ពេលចប់គាត់បែរទៅប្រាប់ម្ចាស់ទូក :

–តា ! បង្វែរក្បាលទូកបង្ហួតក្តោងត្រឡប់ទៅវិញ, ចាំយើងប្រាប់ឲ្យឈប់សឹមឈប់ ! ម្ចាស់ទូកមិនហ៊ានជំទាស់ឆ្លើយបាទ ! ហើយកាច់ចង្កូតបង្វិលទូកត្រឡប់ក្រោយភ្លាម ៗ ជូនចាស់គំហកសួរ :

– ឯងគិតធ្វើអី ?

– យើងនាំឯងទៅកោះខ្យងខៀវដើម្បីព្យាបាលរបួសណា៎ !

– ហ៊ឹះ យើងមិនទៅកោះខ្យងខៀវរបស់ឯងទេ, យើងសុខចិត្តស្លាប់ ៗ មិនទាន់ចាញ់ឯងផង ម៉េចឯងបង្ខំយើងទៅជំរំបិសាចនោះហើយ ?

– អើ ! យើងសន្យាគ្នាហើយតើ ថាប្រយុទ្ធគ្នាលើដងទន្លេឈ្នះកាន់ ៗ កាលណាយើងចាញ់យើងទៅសុំទោសឯងដល់ផ្ទះ, កាលណាឯងចាញ់វិញឯងត្រូវទៅផ្ទះយើងដែរ ៗ ឥឡូវឯងហាក់យុទ្ធសិល្បៈខុសក្បួនមានគ្រោះថ្នាក់ដល់ខ្លួន បានសេចក្តីថាចាញ់យើងហើយតើ ! ឯងត្រូវទៅកោះខ្យងខៀវជាមួយយើង ៗ

ជូនចាស់ខឹងក្រោធគំហកបែកសម្លេង :

– មិនទៅទេ ! មិនទៅ...មិន...

Khmer Story Lovers

(នៅមានត)

ដំកល់ទុកតាមលេខ ៣២៤ ចុះថ្ងៃទី ២៨ - ៥ - ៧០ - បោះពុម្ពលើកទី ១ ចំនួន ២០០០ ច្បាប់